ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖ ១៩២
ចុះថ្ងៃទី ០៥.០៤.២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ ៖ ៦២២ ឈ
ចុះថ្ងៃទី ១៨.០៨.២១

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅសាលជំនុំជំរះសាលាដំបូងខេត្ត កំពង់ចាម នាថ្ងៃទី ១៨.០៨.២០២១ ដែលមានសមាសភាពជំនុំជំរះដូចតទៅ ៖

ចៅក្រមជំនុំជំរះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម

ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

ដើម្បីជំនុំជំរះ ៖

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ១៩២ ចុះថ្ងៃទី ០៥.០៤.២០១៦ ដែលមានជនជាប់ចោទ ៖

ជនជាប់ចោទឈ្មោះ [redacted] **សៅរី** ភេទប្រុស កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៦៧ ជាតិខ្មែរ កើត [redacted] ភ្នំពេញ ឪពុកឈ្មោះ [redacted] ធូរី "ស" ម្តាយឈ្មោះ [redacted] ឡាំងហយ "ស" មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ១១៨E₀ ផ្លូវមុនីវ៉ែត ក្រុម៣៤ ភូមិ៧ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរ កងអង្គរក្សទួលក្រសាំង ប្រពន្ធឈ្មោះ [redacted] ស៊ីណាង មានកូន ០៤នាក់ ជានីតិជន ។

មានមេធាវីការពារសិទ្ធិ ៖ លោក [redacted]
អត្តលេខ [redacted]

ត្រូវជាប់ចោទពីបទ បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ អង្គហេតុកើតនៅភូមិស្រែប្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ែ ភេទប្រុស កើតឆ្នាំ១៩៥៧ ជាតិខ្មែរ កើត និងមានទីលំនៅភូ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] សាំង "ស" ម្តាយឈ្មោះ [redacted] ហួយ "ស" មុខរបរកសិករ ប្រពន្ធឈ្មោះ [redacted] ខេន មានកូន០៥នាក់។

បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៖ ៩០៧ ព.ស ចុះថ្ងៃទី ២២.០៩.២០២០ របស់តំណាង អយ្យការ អមសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញដីកាដំណោះស្រាយលេខ៖១៩៣១ ព.ស ចុះថ្ងៃទី២៩.០៩.២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ។

Scanned with CamScanner

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៖ ១១២៥ ចត ចុះថ្ងៃទី ២៦.១០.២០២០ របស់ប្រធានសាលាដំបូងខេត្តកំង់ចាម ។

បានឃើញ សាលក្រមលេខ ៤៨៧ ·ឈ· ចុះថ្ងៃទី១២.០៥.២០២១ របស់ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញ ពាក្យសុំប្តឹងទាស់ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សៅរី ។

<u>អង្គហេតុជាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ</u>

កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង០៨និង០០នាទីព្រឹក ជនរងគ្រោះឈ្មោះ [redacted] សារ៉ាត ភេទប្រុស អាយុ៤៦ឆ្នាំ ទីលំនៅភូមិអូរតាសែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម បានជិះម៉ូតូ០១គ្រឿ ម៉ាកវ៉េវ ពណ៌ខ្មៅ គ្មានស្លាកលេខ ក្នុងទិសដៅពីលិចទៅកើត ចេញពីកន្លែងចាក់សាំងរបស់ឈ្មោះ ថុល ឆ្លងផ្លូវជាតិលេខ៧១ ស្ថិតនៅភូមិស្រែជ្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម ដើម្បីទៅផ្ទះស្រាប់តែរថយន្ត០១គ្រឿង ម៉ាក LEXUS RX300 ពណ៌ទឹកមាស ស្លាកលេខភ្នំពេញ2U-6661 បើកបរយ៉ាងលឿនក្នុងទិសដៅពីកើតទៅលិច ក៏ជ្រុលទៅបុកម៉ូតូជនរងគ្រោះបណ្តាលឲ្យជនរងគ្រោះរងរបួសបាក់ជើងទាំងពីរ ហើយជនសង្ស័យដែលជាអ្នកបើកបររថយន្ត ក៏បើករថយន្តគេចខ្លួនហើយយករថយន្តទៅទុកចោលនៅចំនុចដីឡូត៍១៧ ខាងជើងភូមិ៣៣ រួចដោះស្លាកលេខយកទៅតាមរត់គេចខ្លួន បន្ទាប់មកសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកចំការលើ ក៏ចុះប្រតិបត្តិការស្រាវជ្រាវរកស៊ប់វែងកន្លែងកើតហេតុ និងបានយកវត្ថុតាងម៉ូតូ និងរថយន្តបង្កខាងលើទៅរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកចំការលើ។ ក្នុងការស្រាវជ្រាវតាមប្រព័ន្ធគ្រប់គ្រងយានយន្តរបស់ក្រសួងសាធារណៈការ និងដឹងជញ្ជូន ឃើញថា រថយន្តម៉ាកLEXUS RX300 ពណ៌ទឹកមាស ស្លាកលេខភ្នំពេញ2U-6661 មានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] សៅរី ទីលំនៅផ្ទះលេខ ១១៨ E_0 ផ្លូវមុន្នីរ៉ែត សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្ទាប់មកសមត្ថកិច្ចក៏បាន កសាងសំណុំរឿងបញ្ជូនមកតុលាការ។ដោយឡែកវត្ថុតាងម៉ូតូ និងរថយន្តខាងលើត្រូវបានសមត្ថកិច្ចរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកចំការលើ។

<u>អង្គច្បាប់ដែលជាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ</u>

-<u>មាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក</u> ៖

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យរបួសដល់អ្នកដទៃ ហើយបណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើ ឬលើសពី ៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផន្តាទោសដាក់ពន្ធនាគារ ពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា ៥៣(ប្រភេទនៃទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ ។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ឆ្នាំ ទៅ ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១៥ ០០០ ០០០(ដប់ប្រាំលាន)រៀល កាលបើអំពើនេះបានប្រព្រឹត្តក្នុងករណីណាមួយ ដូចក្រោម ៖

Scanned with CamScanner

ក-បើកបរដោយគ្មានបណ្ណបើកបរ ឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ-ស្ថិតនៅក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី ០,៤០(សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រខ្យល់ឡើងទៅ ។

គ-បណ្តាលឲ្យមានរបួសមនុស្សច្រើននាក់ ។

ឃ-រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ: ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស:

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ: កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្តាពរ ឬសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ យ៉ានច្រើន។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ យ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ។

៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២(ពីរ)ខែយ៉ាងច្រើន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨(ប្រាំបី)ថ្ងៃ យ៉ាងច្រើន ។

<u>អង្គហេតុដែលបានលើកឡើងនាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **សៅរី បំភ្លឺថា ៖** រថយន្ត០១គ្រឿង ម៉ាក LEXUS RX300 ពណ៌ទឹកមាស ស្លាកលេខ ភ្នំពេញ2U-6661 ពិតជារថយន្តរបស់ខ្ញុំមែន ប៉ុន្តែខ្ញុំមិនបានបើកឡានបង្កគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យគេរបួសទេ ដោយសារតែឡានរបស់ខ្ញុំខាងលើត្រូវបានឈ្មោះ ញ៉ាញ់ លួចយកទៅបាត់តាំងពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ ម្ល៉េះ ពេលនោះ ហើយខ្ញុំក៏បានដាក់ពាក្យបណ្តឹងដែរ ។ ដើមឡើយគឺខ្ញុំបានទៅធ្វើជាទាហាននៅសមរភូមិ ក៏បានជួប និងស្គាល់ឈ្មោះ ញ៉ាញ់ នេះ នៅហាងកាហ្វេ ដោយសារវាជាក្មេងឧស្សាហ៍មកជួយខ្លួនធ្វើការ ព្រឹកៗឡើង ឃើញវាមកសុំជួយខ្ញុំធ្វើនេះ ធ្វើនោះ យូៗទៅ ខ្ញុំក៏ទុកចិត្តឱ្យវាជួយជាធុរៈ យកឡានទៅលាង ទៅផ្សារទិញរបស់របរ ដោយនៅយូៗទៅវាដឹងចិត្តខ្ញុំ ទុកចិត្តឱ្យវាអាចប្រើឡានខ្ញុំទៅបំពេញធុរៈ ឬទៅទិញអីបាន ស្រាប់តែនៅថ្ងៃទី ៣០.០១. ២០១៦ ពេលព្រឹក ខ្ញុំកំពុងតែធ្វើការអូសខ្សែរអង់តែន ពេលត្រឡប់មកវិញ ក៏បានបាត់ឡានទៅហើយ ចំណែកឈ្មោះ ញ៉ាញ់ ក៏បាត់មកឃើញដូចគ្នា ចាំយូៗទៅមិនឃើញវាយកឡានខ្ញុំត្រឡប់មកវិញទេ ដោយសារតាមទម្លាប់វាយកទៅតែមួយភ្លែតៗទេ ក៏មកវិញហើយ តែនេះ វាយកទៅបាត់តាំងពីព្រឹក ខ្ញុំក៏បានទូរស័ព្ទទៅលោក ប៉ូ ដោយប្រាប់ថា ឈ្មោះ ញ៉ាញ់ យកឡានជិះទៅបាត់ឈឹងតែម្តង។ ក្រោយពីប្រាប់រួច លោក ប៉ូ បានផ្តល់យោបល់ឱ្យខ្ញុំ ដាក់ពាក្យបណ្តឹងទៅ ដោយក្នុងឡាននោះ នៅមានកាំភ្លើងរបស់ខ្ញុំទៀត ។ សូមបញ្ជាក់ថា នៅក្នុងអង្គភាពខ្ញុំ គ្រាន់តែបាត់ត្រឹមឯកសារសំខាន់ផ្ទាល់ខ្លួន អត្តសញ្ញាណប័ណ្ណ ក៏ត្រូវជូនដំណឹងដែរ ។ កន្លងមក ខ្ញុំដឹងត្រឹមតែវាឈ្មោះ ញ៉ាញ់ ភេទប្រុស (អាយុក្មេង) មានកំពស់ប្រហែល១.៥៥ម៉ែត្រ ជាអ្នករស់នៅតំបន់នោះ ខ្ញុំមិនដែលបាន

Scanned with CamScanner

Scanned with CamScanner

ដេញដោលសួរសោរតាវានោះទេ ។ ចាប់តាំងពីដាក់ពាក្យបណ្តឹងមក ខ្ញុំមិនដែលបានទទួលដំណឹង ឬព័ត៌មាន ពាក់ព័ន្ធនឹងឡានខ្ញុំ ឬក៏ឈ្មោះ ញ៉ាញ់ នេះទេ ពោលគឺវាយកឡានខ្ញុំចេញទៅបាត់ស្ងាត់ឈឹង ប៉ុន្តែស្រាប់តែថ្មីៗនេះ ខ្ញុំបានទទួលដំណឹងសាលក្រមកំពាំងមុខរបស់តុលាការ ខេត្តកំពង់ចាម ថាខ្ញុំពាក់ព័ន្ធនឹងរឿងគ្រោះថ្នាក់ចរាចរណ៍ទៅវិញ តែអំឡុងពេលនោះ ខ្ញុំពិតជាបាត់ឡានមែន ដោយឈ្មោះ ញ៉ាញ់ ជាអ្នកយកទៅ ។ ក្រៅអំពីលិខិតជូនដំណឹងអំពីសាលក្រមកំពាំងមុខ ដែលខ្ញុំទើបទទួលបាន ខ្ញុំមិនដែលទទួលបានដីកាកោះណាមួយពីតុលាការឡើយ។ ខ្ញុំបានទៅធ្វើការនៅព្រំដែន ខាងព្រះវិហារ នៅក្នុងឆ្នាំ២០០៨ ទទួលខុសត្រូវខាងវិទ្យុទាក់ទង ។ ចំពោះឈ្មោះ ញ៉ាញ់ វាជាក្មេង នៅតំបន់នោះដែរ វាតែងមកជួយធ្វើការខ្ញុំរហូតដល់បានស្គាល់ គ្រាន់តែខ្ញុំមិនបានដេញដោល សួរនាំសារតាវាទេ ឃើញថា វាជាក្មេងឧស្សាហ៍ស្លូតបូត ទើបទុកចិត្ត មិននឹកស្មានថាវា ហ៊ានធ្វើបែបនេះទេ។ ខ្ញុំបាទសំណូមពរ ឱ្យលោកចៅក្រម មេត្តាសម្រេចឱ្យខ្ញុំរួចខ្លួនពីបទចោទប្រកាន់ដោយអនុគ្រោះ ទោះជាខ្ញុំមិនបានប្រព្រឹត្តក៏ដោយ ក៏ប៉ុន្តែ ខ្ញុំបាទសូមទទួលខុសត្រូវសំណងរដ្ឋប្បវេណីមួយផ្នែក ក្នុងនាមជាម្ចាស់ឡាន។

-**សាក្សីឈ្មោះ [redacted] បូរ៉ា ហៅ រកាកោង បានបំភ្លឺថា ៖** ខ្ញុំបាទជាសាក្សីក្នុងរឿងនេះ ខ្ញុំបាទមិនមានជាប់សាច់ញាតិអ្វីជាមួយឈ្មោះ [redacted] សៅរី ទេ ខ្ញុំបាទបានស្បថរួចហើយ។ នៅថ្ងៃទី ៣០.០១.២០១៦ ខ្ញុំបាទពិតជាបានទទួលទូរស័ព្ទពីឈ្មោះ [redacted] សៅរី ពិតមែន ដោយគាត់បាននិយាយថា ឈ្មោះ ញ៉ាញ់ បានយកឡានគាត់ទៅបាត់ឈឹង មិនឃើញត្រឡប់មកវិញទេ ដោយក្នុងឡាននោះ នៅមានកាំភ្លើង មានអីទៀត លីបែបនេះ ខ្ញុំបានណែនាំឱ្យគាត់ដាក់ពាក្យបណ្តឹង ទៅប៉ុស្តិ៍ និងទៅអង្គភាពទៅ ។ កាលនោះ ខ្ញុំមានតួនាទីជា ប្រធានការិយាល័យសន្តិសុខបញ្ជាការដ្ឋានកងអង្គរក្ស នៅបន្ទាយទួលក្រសាំង។ ខ្ញុំដឹងរឿងតែប៉ុណ្ណឹងទេ។

-**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖** ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ តំណាងអយ្យការសូមធ្វើសេចក្តីសន្និដ្ឋានថា៖ ផ្អែកតាមចម្លើយរបស់ជនជាបទចោទឈ្មោះ [redacted] សារី បានឆ្លើយថា ឡានរបស់ខ្លួនត្រូវបានឈ្មោះ ញ៉ាញ់ លួចយកទៅបាត់ តាំងពីថ្ងៃទី៣០.០១.២០១៦ មកម្ល៉េះ ដោយខ្លួនបានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] បូរ៉ា ហើយគាត់បានផ្តល់យោបល់ថាឱ្យខ្លួនដាក់ពាក្យប្តឹង ហើយខ្លួនក៏បានដាក់ពាក្យប្តឹងនៅប៉ុស្តិ៍ និងនៅអង្គភាពរបស់ខ្លួន ហើយក្រោយពីដាក់ពាក្យប្តឹងមក ឈ្មោះ ញ៉ាញ់ និងឡានរបស់ខ្លួន គឺបាត់ដំណឹងសូន្យ រកមិនឃើញ ទើបតែថ្មីៗ ខ្លួនបានទទួលដំណឹងអំពីសាលក្រមកំពាំងមុខផ្តន្ទាទោសខ្លួនលើករណីគ្រោះថ្នាក់ចរាចរណ៍ទៅវិញ ដែលចម្លើយនេះ មានលក្ខណៈស្របគ្នាជាមួយសាក្សីឈ្មោះ [redacted] បូរ៉ា ថា នៅថ្ងៃទី៣០.០១.២០១៦ ខ្លួនពិតជាបានទទួលទូរស័ព្ទពីឈ្មោះ [redacted] សៅរី ពិតមែន ដោយគាត់បាននិយាយថា ឈ្មោះ ញ៉ាញ់ បានយកឡានគាត់ទៅបាត់ឈឹង មិនឃើញត្រឡប់មកវិញទេ ដោយក្នុងឡាននោះ នៅមានកាំភ្លើង មានអីទៀត លីបែបនេះ ខ្លួនបានណែនាំឱ្យគាត់ដាក់ពាក្យបណ្តឹង ទៅប៉ុស្តិ៍ និងទៅអង្គភាពទៅ ។ តាមចម្លើយជនជាប់ចោទ និងសាក្សី បញ្ជាក់ថា ឡានរបស់ឈ្មោះ [redacted] សៅរី ត្រូវបានឈ្មោះ ញ៉ាញ់ លួចយកទៅបាត់ នៅថ្ងៃទី៣០.០១. ២០១៦ ហើយករណីគ្រោះថ្នាក់ចរាចរណ៍ក្នុងសំណុំរឿងនេះ កើតឡើងនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បន្ទាប់ពីបានបាត់ឡានរយៈពេល៨ថ្ងៃ អាចបញ្ជាក់បានថា អ្នក

Scanned with CamScanner

ដែលបើកបរឡានបង្កគ្រោះថ្នាក់ចរាចរណ៍ មិនមែនជនជាប់ចោទឈ្មោះ [redacted] សារី ទេ។ ហេតុដូច្នេះ តំណាងអយ្យការ ប្តឹងសុំលោកចៅក្រម សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សារី រួចផុតពីបទចោទ ។ ស្បិតយ៉ាងនេះក្តី តាមប័ណ្ណសម្គាល់យានយន្ត បានបញ្ជាក់ថា ឈ្មោះ [redacted] សៅរី គឺជាម្ចាស់រថយន្ត ដែលមានផ្លាកលេខ 2U-6661 ហេតុនេះ ក៏ត្រូវទទួលខុសត្រូវទៅលើសំណងរដ្ឋប្បវេណីទៅលើជនរងគ្រោះ មួយផ្នែក រីឯមួយផ្នែកទៀត គឺជាការទទួលខុសត្រូវរបស់ឈ្មោះ ញ៉ាញ់ ដែលបានលួចរថយន្ត និងជាអ្នកបើកបរបង្កគ្រោះថ្នាក់ចរាចរណ៍។

-លោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] សៅរី ធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ ជាបឋម ខ្ញុំបាទ និងនាងខ្ញុំ សូមគោរព លោកចៅក្រមជំនុំជម្រះ លោកតំណាងអយ្យការ និងអង្គសវនាការទាំងមូល ខ្ញុំបាទ និងនាងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៅរី សូមធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីការសាកសួរដេញដោលនាពេលសវនាការនេះ កូនក្តីខ្ញុំបាទ និងនាងខ្ញុំ គាត់បានឆ្លើយនៅចំពោះមុខតុលាការ និងអង្គសវនាការ គឺគាត់បានបញ្ជាក់ថា គាត់មិនបានជាអ្នកប្រើប្រាស់រថយន្តនេះទេ អ្នកដែលប្រើប្រាស់រថយន្តបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍នោះ គឺឈ្មោះ ញ៉ាញ់ ហេតុដូច្នេះសូមឱ្យតុលាការមេត្តាពិចារណាលើការចោទប្រកាន់នេះ មានវិមតិសង្ស័យទៅលើជនជាប់ចោទ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ចំណុចមួយទៀត តាមមាត្រា ២៤ នៃក្រហ្មទណ្ឌ ផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃទោស ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ កូនក្តី ខ្ញុំបាទ និងនាងខ្ញុំ ពុំមែនជាអ្នកប្រព្រឹត្ត សូមឱ្យតុលាការ មេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតពីចោទចោទប្រកាន់ ព្រោះកូនក្តីខ្ញុំបាទ និងនាងខ្ញុំ ពុំមែនជាអ្នកបើកបររថយន្តនោះទេ គាត់គ្រាន់តែជាអ្នកបើកបររថយន្ត និងផ្អែកតាមមាត្រា ៧២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក កូនក្តីខ្ញុំបាទ និងនាងខ្ញុំ ច្បាស់ណាស់ថា គាត់មានប័ណ្ណសម្គាល់យានយន្តថា រថយន្តនោះជារបស់គាត់ ទោះគាត់មិនបានប្រព្រឹត្ត ក៏ប៉ុន្តែគាត់សុំទទួលខុសត្រូវសំណងរដ្ឋប្បវេណី ហើយសុំឱ្យតុលាការពិចារណា បន្ធូរបន្ថយសំណងរដ្ឋប្បវេណីអោយផង ។ លើសពីនេះទៅទៀត ក្នុងនាមខ្ញុំបាទ និងនាងខ្ញុំ ជាមេធាវីការពារសិទ្ធិ ស្នើសុំឱ្យតុលាការ មេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទចោទ និងសូមឱ្យចេញដីកាបញ្ឈប់ឱ្យចាប់ខ្លួនកូនក្តីខ្ញុំបាទ និងនាងខ្ញុំ ដោយអនុគ្រោះ។

ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់ចំលើយរបស់សាក្សី
ក្រោយពីបានស្តាប់អំណានចំលើយរបស់ដើមបណ្តឹង និងជាជនរងគ្រោះ
ក្រោយពីបានស្តាប់ការសួរដេញដោល
ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ តុលាការវិនិច្ឆ័យសេចក្តីដូចតទៅ៖

Scanned with CamScanner

Scanned with CamScanner

សំអាងហេតុ

១.តាមសាលក្រមកំចាំងមុខលេខ ៤៤៧ "ឈ" ចុះថ្ងៃទី១២.០៥.២០២១ របស់សាលក្រមសាលាដំបូង ដែលបានវិនិច្ឆ័យសេចក្តីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សៅរី ភេទប្រុស កើតថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៦៧ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ) ជាក់ពន្ធនាគារចំនួន ០១(មួយ)ឆ្នាំ ពី **បទបើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** អង្គហេតុកើតនៅភូមិស្រែជ្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២.ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងឯកសារដែលប្រមូលបាននៅដំណាក់កាលស៊ើបសួរ ឃើញថា តុលាការយល់ឃើញថា ពិតជាមានអង្គហេតុគ្រោះថ្នាក់ចរាចរណ៍ បង្កឡើងដោយរថយន្ត០១គ្រឿង ម៉ាក LEXUS RX300 ពណ៌ទឹកមាស ស្លាកលេខ ភ្នំពេញ2U-6661 បានបើកបរក្នុងល្បឿនលឿនហើយជ្រុលចង្កូតទៅបុកម៉ូតូជនរងគ្រោះឈ្មោះ [redacted] សារ៉ាត បណ្តាលឲ្យជនរងគ្រោះរងរបួសបាក់ជើងទាំងពីរ ហើយជនសង្ស័យដែលជាអ្នកបើកបររថយន្ត ក៏បើករថយន្តគេចខ្លួនហើយយករថយន្តទៅទុកចោលនៅចំនុចដីឡូត៍១៧ ខាងជើងភូមិ៣៣ជ។ តាមរយៈការស្រាវជ្រាវតាមប្រព័ន្ធគ្រប់គ្រងយានយន្តរបស់ក្រសួងសាធារណៈការ និងដឹងជញ្ជូន បានកំណត់អត្តសញ្ញាណម្ចាស់កម្មសិទ្ធិកររបស់រថយន្តម៉ាកLEXUS RX300 ពណ៌ទឹកមាស ស្លាកលេខ ភ្នំពេញ2U-6661 គឺឈ្មោះ [redacted] សៅរី ទីលំនៅផ្ទះលេខ ១១៨ E_0 ផ្លូវមុន្នីរ៉េត សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្ទាប់មកសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការ ហើយតំណាងអយ្យការបានសម្រេចចោទប្រកាន់ឈ្មោះ [redacted] សៅរី ពីបទ **បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** រហូតដល់ដំណាក់កាលជំនុំជម្រះ និងបានចេញសាលក្រមកំចាំងមុខលេខ ១៩២ ចុះថ្ងៃទី០៥.០៤.២០១៦ ។

ប៉ុន្តែ ក្រោយពីទទួលបណ្តឹងទាស់ និងបើកសវនាការធ្វើការជំនុំជម្រះជាសាធារណៈម្តងទៀតដោយពិនិត្យភស្តុតាង ឯកសារដែលប្រមូលបាននៅក្នុងសំណុំរឿង និងក្រោយពីការសួរដេញដោលលើជនជាប់ចោទ និងសាក្សី តុលាការយល់ឃើញថា មានវិមតិសង្ស័យលើជនជាប់ចោទឈ្មោះ [redacted] សារី ពីបទ**បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** ដោយហេតុថា ៖

នៅក្នុងសំណុំរឿងនេះ ការកំណត់អំពីអត្តសញ្ញាណជនល្មើស ដែលបានបើកបរបង្កគ្រោះថ្នាក់ចរាចរណ៍ គឺតាមរយៈ ការស្រាវជ្រាវតាមប្រព័ន្ធគ្រប់គ្រងយានយន្តរបស់ក្រសួងសាធារណៈការ និងដឹងជញ្ជូន ដើម្បីកំណត់ថា អ្នកណាជាម្ចាស់របស់រថយន្តម៉ាកLEXUS RX300 ពណ៌ទឹកមាស ស្លាកលេខ ភ្នំពេញ2U-6661ជាលទ្ធផល គឺជនជាប់ចោទឈ្មោះ [redacted] សៅរី ជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែក្រៅពីនេះ គឺពុំមានសាក្សីណាម្នាក់ បានឃើញហេតុការណ៍ និងកំណត់ចំណាំអត្តសញ្ញាណជនប្រព្រឹត្តិ ដែលបើកឡានបុកជនរងគ្រោះផ្ទាល់ភ្នែកទេ ដោយមានសាក្សីឈ្មោះ [redacted] ចាន់ភីណា សាក្សីឈ្មោះ [redacted] ស្រីនី គ្រាន់តែបានបំភ្លឺប្រហាក់ប្រហែលគ្នាថា ឃើញរថយន្តបុកម៉ូតូ ពេលបុករួចរថយន្ត បានបើកទៅទិសខាងត្បូងបាត់ ។

Scanned with CamScanner

Scanned with CamScanner

ប៉ុន្តែផ្ទុយទៅវិញ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សៅរី បានឆ្លើយថា៖ ឡានរបស់ខ្លួនត្រូវបានឈ្មោះ ញ៉ាញ់ លួចយកទៅបាត់ តាំងពីថ្ងៃទី៣០.០១. ២០១៦ មកម្ល៉េះ ដោយខ្លួនបានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ប៉ូរ៉ា ហើយគាត់បានផ្តល់យោបល់ថា ឱ្យខ្លួនដាក់ពាក្យប្តឹង ហើយខ្លួនក៏បានដាក់ពាក្យប្តឹងនៅប៉ុស្តិ៍ និងនៅអង្គភាពរបស់ខ្លួន ហើយក្រោយពីដាក់ពាក្យប្តឹងមក ឈ្មោះ ញ៉ាញ់ និងឡានរបស់ខ្លួន គឺបាត់ដំណឹងសូន្យ រកមិនឃើញ ទើបតែថ្មីៗ ខ្លួនបានទទួលដំណឹងអំពីសាលក្រមកំពាំងមុខផ្តន្ទាទោសខ្លួនលើករណីគ្រោះថ្នាក់ចរាចរណ៍ទៅវិញ ។ ចំពោះការស្គាល់ឈ្មោះ ញ៉ាញ់ ដើមឡើយគឺខ្លួនបានទៅធ្វើជាទាហាននៅសមរភូមិ ក៏បានជួប និងស្គាល់វានេះ នៅហាងការ៉ាអូ ដោយសារវាជាក្មេងឧស្សាហ៍មកជួយខ្លួនធ្វើការ ព្រឹកៗឡើង ឃើញវាមកសុំជួយខ្លួនធ្វើនេះ ធ្វើនោះ យូៗទៅ ខ្លួនក៏ទុកចិត្តឱ្យវាជួយជាធុរៈ យកឡានទៅលាង ទៅផ្សារទិញរបស់របរ ដោយនៅយូៗទៅវាក៏ដឹងចិត្តខ្លួនខ្លួនក៏មិននឹកស្មានថា វាហ៊ានលួចយកឡានខ្លួនទៅដែរ ដោយសារវាជាក្មេង នៅតំបន់នោះដែរ វាតែងមកជួយធ្វើការខ្ញុំរហូតដល់បានស្គាល់ គ្រាន់តែខ្ញុំមិនបានជេញដោល សួរនាំសាវតាវាទេ ឃើញថា វាជាក្មេងឧស្សាហ៍ស្លូតបូត ទើបទុកចិត្ត មិននឹកស្មានថាវា ហ៊ានធ្វើបែបនេះទេ។

ស្របគ្នាជាមួយចម្លើយសាក្សីឈ្មោះ [redacted] ប៉ូរ៉ា បានឆ្លើយថា៖ នៅថ្ងៃទី៣០.០១.២០១៦ ខ្លួនពិតជាបានទទួលទូរស័ព្ទពីឈ្មោះ [redacted] សៅរី ពិតមែន ដោយគាត់បាននិយាយថា ឈ្មោះ ញ៉ាញ់ បានយកឡានគាត់ទៅបាត់ឈឹង មិនឃើញត្រឡប់មកវិញទេ ដោយក្នុងឡាននោះ នៅមានកាំភ្លើង មានអីទៀត លីបែបនេះ ខ្លួនបានណែនាំឱ្យគាត់ដាក់ពាក្យបណ្តឹង ទៅប៉ុស្តិ៍ និងទៅអង្គភាពទៅ ។ កាលនោះ ខ្លួនមានតួនាទីជា ប្រធានការិយាល័យសន្តិសុខបញ្ជាការដ្ឋានកងអង្គរក្ស នៅបន្ទាយទួលក្រសាំង។

តាមចម្លើយរបស់ជនជាប់ចោទ និងសាក្សី ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សៅរី ពិតជាបានបាត់ឡាន ដោយឈ្មោះ ញ៉ាញ់ ជាអ្នកលួចយកទៅបាត់ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ ប្រាកដមែន ហើយថ្ងៃកើតហេតុ(គ្រោះថ្នាក់ចរាចរណ៍) គឺនៅថ្ងៃទី០៣.០២.២០១៦ តាមរយៈពេលការផ្ទៀងផ្ទាត់ នៃវេលានេះ អាចបញ្ជាក់ឱ្យឃើញថា៖ អ្នកដែលបើកបររថយន្តបង្កគ្រោះថ្នាក់ចរាចរណ៍ គឺពុំមែនឈ្មោះ [redacted] សៅរី ទេ ពោលគឺមានអ្នកផ្សេងម្នាក់ទៀត ។ ហេតុនេះ គប្បីតុលាការ សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សៅរី រួចខ្លួនពីបទចោទប្រកាន់ បទបើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ ។

៣. តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានសុំឲ្យតុលាការ សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **សៅរី រួចខ្លួនពីបទ បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** មានលក្ខណៈត្រឹមត្រូវ ដោយហេតុផលដូចខាងលើ ។

៤. ពុំមានធាតុផ្សំគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សៅរី** ភេទប្រុស កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៦៧ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ) **ពីបទ បើកបររដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** អង្គហេតុកើតនៅភូមិស្រែជ្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

Scanned with CamScanner

ខ្លួនក្នុងនាមជាម្ចាស់ឡានផងដែរ។ ហេតុដូច្នេះ តុលាការសម្រេចបង្គាប់ឱ្យឈ្មោះ [redacted] សៅរី ទទួលខុសត្រូវសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងក្នុងចំណែក ៥០% នៃការទាមទារ និងការសម្រេចដែលមាននៅក្នុងសាលក្រមលេខ៤៤៧ -ឈ- ចុះថ្ងៃទី១២.០៥.២០២១ របស់សាលាដំបូង ខេត្តកំពង់ចាម ចំពោះ ៥០%ទៀត គឺជាចំណែកទទួលខុសត្រូវរបស់អ្នកបើកបរ (មិនស្គាល់អត្តសញ្ញាណ) ដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍នេះ ។

៦.ចំពោះវត្ថុចាប់យក ម៉ូតូ ម៉ាក វ៉ៃវ៉ាឡាម គ្មានស្លាកលេខ ដែលជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted] សារ៉ាត់ និងត្រូវជាប្អូនបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យើ។ ដូចនេះ គប្បីតុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ មាត្រា៦២កថាខណ្ឌ២នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ហេតុដូច្នេះ តុលាការសម្រេច

១.ឱ្យជនជាប់ចោទឈ្មោះ [redacted] **សៅរី** ភេទប្រុស កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៦៧ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ) **រួចខ្លួនពីបទចោទប្រកាន់បទ បើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យមានរបួសអ្នកដទៃ** អង្គហេតុកើតនៅភូមិស្រែជ្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២. បង្គាប់ឲ្យឈ្មោះ [redacted] **សៅរី** ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមួយផ្នែក សងសំណងជម្ងឺចិត្តឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **យើ** ចំនួន ១៧៥០(មួយពាន់ប្រាំពីររយហាសិប)ដុល្លាអាមេរិក ។

៣. បញ្ឈប់ការចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សៅរី** ភេទប្រុស កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៦៧ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ) ដែលមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ៥៦៥ ព.ស ចុះថ្ងៃទី ២៨.៦.២០២១ ភ្លាម ។

៤.វត្ថុចាប់យក៖ ម៉ូតូ ម៉ាក វ៉ៃវ៉ាឡាម គ្មានស្លាកលេខ ប្រគល់ឲ្យឈ្មោះ [redacted] យើ ជាដើមបណ្តឹងរដ្ឋប្បវេណី និងជាបងបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] សារ៉ាត់ ។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៨.០៨.២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សៅរី** និងកំចាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **យើ** ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ និងប្តឹងទាស់ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និងត្រា [redacted]
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ
ចៅក្រមជំនុំជំរះ

ថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ចាម ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០២១
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner